# មេរៀនទី ៦៥៖ ព្រះយេស៊ូវប្រោសមនុស្សខ្វាក់ឲ្យជា

## ម៉ាកុស ១០៖៤៦-៥២

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/eEteKPqoN5Q

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/Ta6_ZdiqPqM

**គោលបំណង៖** យើងមានសេចក្ដីជំនឿលើព្រះយេស៊ូវ។

**ខគម្ពីរចងចាំ៖**
**កិច្ចការ ១០៖៣៨** *"គឺពីព្រះយេស៊ូវ ពីស្រុកណាសារ៉ែត ដែលព្រះបានចាក់ព្រះវិញ្ញាណបរិសុទ្ធ និងព្រះចេស្ដា ឲ្យមកសណ្ឋិតលើទ្រង់ ហើយទ្រង់បានយាងចុះឡើងធ្វើការល្អ ព្រមទាំងប្រោសឲ្យអស់អ្នកដែលត្រូវអារក្ស សង្កត់សង្កិនបានជាផង ដ្បិតព្រះបានគង់ជាមួយនឹងទ្រង់"។*

**ចំរៀង** ( *យូធូបលីង* )៖
១.មានទន្លេជីវិត https://youtu.be/AP6fwLxUqK0
២.ព្រះយេស៊ូវមករកមនុស្សមានបាប https://youtu.be/KuGfv2U0YmE
៣.ខ្ញុំនឹងទុកចិត្តទ្រង់ https://youtu.be/WCZlwlstAzc

**១. អធិស្ឋាន**

**២. ចំរៀង** ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

**៣. ល្បែងកំសាន្ត** « **ដឹកដៃមនុស្សខ្វាក់** »

សម្ភារៈដែលត្រូវការ៖ក្រណាត់សម្រាប់រុំភ្នែក របស់របរដើម្បីបង្កើតជាឧបសគ្គ( កៅអី ដុំថ្ម ដបទឹក ។ល។)



១. ចែកកុមារជា ២ឬ ៤ក្រុម អាស្រ័យលើចំនួនកុមារ



២. ជ្រើសរើសកុមារ ២នាក់ ដើម្បីធ្វើជាតំណាងក្រុមនីមួយៗ។ ម្នាក់ត្រូវដើរតួជាកុមារពិការហើយគេត្រូវបិទភ្នែក និងម្នាក់ទៀតដើរតួជាអ្នកនាំផ្លូវ ។

៣. គ្រូត្រូវដាក់ឧបសគ្គនៅក្នុងថ្នាក់រៀន ( កៅអី ដុំថ្ម និងដបទឹក ។ល។)

៤. កុមារដែលជាអ្នកនាំផ្លូវកុមារពិការភ្នែកឆ្លងកាត់ឧបសគ្គពីផ្នែកម្ខាងនៃថ្នាក់រៀន ដោយក្រុមទាំងពីរត្រូវចាប់ផ្ដើមពីទិសដៅផ្ទុយគ្នា។

៥. កុមារដែលជាអ្នកនាំផ្លូវត្រូវប្រាប់កុមារដែលត្រូវគេបិតភ្នែកនោះ ឲ្យដើរជាន់លើជើងកុមារ ដែលត្រូវគេបិតភ្នែករបស់ក្រុមម្ខាងទៀត។ ហើយប្រសិនបើកុមារបិទភ្នែកណាដែលជាន់លើជើងបានមុន ក្រុមនោះជាអ្នកឈ្នះ។

**៤. ការណែនាំមេរៀន**

**សកម្មភាព៖** គ្រូកុមារនាំកុមារដើរនៅក្នុងថ្នាក់រៀនរបស់ពួកគេ ដោយឲ្យកុមារទាំងអស់បិទភ្នែកហើយគ្រូស្រែកឲ្យកុមារដើរទៅឆ្វេងស្តាំទៅមុខទៅក្រោយ ។ បន្ទាប់ពីធ្វើសកម្មភាពនេះរួច ឲ្យកុមាទាំងអស់បើកភ្នែក

វិញរួចអង្គុយចុះ ហើយសួរពួកគេថា។

តើប្អូនពិបាកដើរដែរឬទេនៅពេលយើងពិការភ្នែកបែបនេះ? វាជាការពិបាកណាស់ ក្នុងការរស់ដោយយើងមិនអាចមើលអ្វីឃើញនោះ។ ថ្ងៃនេះយើងនឹងរៀនអំពីបុរសពិការភ្នែកម្នាក់ដែលគាត់បានពិការភ្នែក បន្ទាប់ពីគាត់បានកើតរួចហើយ។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ថ្ងៃមួយខណៈពេលដែលព្រះយេស៊ូវនិងពួកសិស្សរបស់ទ្រង់បានដើរឆ្លងកាត់បុរសម្នាក់ដែលមានឈ្មោះថាបារទីមេ។ បារទីមេគឺកំពុងតែអង្គុយនៅតាមផ្លូវ ដើម្បីសុំទានដោយសារតែគាត់មិនអាចមើលអ្វីឃើញនោះទេ។ នៅពេលដែលគាត់បានដឹងថា ព្រះយេស៊ូវយាងកាត់ទីនោះ គាត់ក៏ស្រែកឡើងថា "សូមអាណិតមេត្តាទូលបង្គំផង!" មនុស្សម្នាដែលនៅជិតគាត់បានប្រាប់ឲ្យគាត់ស្ងាត់ទៅ ប៉ុន្តែគាត់មិនបានឈប់នោះទេ។ នៅពេលដែលព្រះយេស៊ូវបានឮ ទ្រង់ក៏បានឈប់ហើយហៅបារទីមេឲ្យមកជិតព្រះអង្គ។

ព្រះយេស៊ូវបានសួរគាត់ថា តើចង់ឲ្យខ្ញុំធ្វើអ្វីដល់អ្នក បារទីមេក៏បានឆ្លើយថា "លោកគ្រូអើយ សូមឲ្យខ្ញុំបានមើលឃើញម្តងទៀត"។ យើងអាចដឹងថាគាត់ធ្លាប់មើលឃើញពីមុន ដោយព្រោះគាត់បាននិយាយថា "សូមឲ្យខ្ញុំបានមើលឃើញម្តងទៀត"។ នៅពេលដែលព្រះយេស៊ូវបានឮដូច្នេះទ្រង់តបថា "ទៅចុះ សេចក្តីជំនឿអ្នកបានសង្គ្រោះអ្នកហើយ" ហើយរំពេចនោះបារទីមេក៏បានមើលឃើញវិញ។

ព្រះយេស៊ូវមិនបានសួរគាត់ថា តើអ្នកមានដើរតាមបទបញ្ញត្តិទាំង ១០ ប្រការឬអត់នោះទេ។ ទ្រង់មិនបានឲ្យគាត់ទំលាក់គ្រប់ទាំងអស់នោះទេ។ ហើយទ្រង់ក៏មិនបានឲ្យគាត់ ធ្វើការសន្យាក្នុងការជួយអ្នកដ៏ទៃត្រូវទៅព្រះវិហារ ឬក៏ប្រាប់អ្នកដ៏ទៃអំពីព្រះវបិតាឬក៏ព្រះយេស៊ូវនោះដែរ។

ហើយបារទីមេក៏មិនបានធ្វើកិច្ចការទាំងអស់នោះដែរ តែព្រះយេស៊ូវបានប្រោសគាត់ឲ្យជា។ តើអ្នកដឹងថាមូលហេតុអ្វីដែរឬទេ? ពីព្រោះព្រះអង្គមិនបានសុំឲ្យយើងមកទទួលព្រះគុណរបស់ទ្រង់នោះទេ។ យើងមិនសមទទួលបានព្រះគុណនោះទេ ប៉ុន្តែយ៉ាងណាក៏ដោយព្រះចង់ឲ្យវាមកយើង។ ដូច្នេះជំនួសឲ្យការដែលយើងទទួលបានព្រះគុណនោះ ព្រះអង្គចង់ឲ្យយើងមានសេចក្តីជំនឿ និងទូលសូមព្រះគុណពីព្រះ។

ដើម្បីទៅឯនគរស្ថានសួគ៌បាន អ្នកត្រូវតែទទួលបាននូវសេចក្តីសង្គ្រោះជាមុនសិន។ ប៉ុន្តែ តើអ្នកអាចទិញសេចក្តីសង្គ្រោះបានដែរឬទេ? ទេ អ្នកមិនអាចទេ។ គ្រប់ការទាំងអស់ដែលព្រះចង់ឲ្យយើងធ្វើគឺ មានសេចក្តីជំនឿនិងទូលសុំពីព្រះ។ នេះគឺជាអ្វីដែលយើងត្រូវធ្វើ។ យើងមិនអាចទិញវានោះទេ ប៉ុន្តែព្រះអង្គនឹងប្រទានឲ្យដល់យើងនៅពេលដែលយើងចេះទូលសុំ សូមមានជំនឿថាទ្រង់នឹងប្រទានវាឲ្យដល់យើង។

ព្រះជាម្ចាស់តែងតែចង់ឲ្យយើងធ្វើនូវអ្វីដែលល្អបំផុត។ ហើយទ្រង់នៅតែចង់ឲ្យយើងដើរតាមបញ្ញត្តិទាំង ១០ប្រការ ទៅព្រះវិហារ ប្រាប់អ្នកដទៃអំពីព្រះយេស៊ូវ យើងត្រូវការមានសេចក្តីជំនឿ ហើយទូលសុំព្រះឲ្យជួយសង្គ្រោះដល់យើង ចូរជឿថាទ្រង់នឹងធ្វើវា ហើយត្រូវព្យាយាមឱ្យអស់ពីសមត្ថភាពរបស់យើងចំពោះអ្វីៗផ្សេងទៀត។

## ៦. សំនួរពិភាក្សា

១. តើបុរសពិការភ្នែកនោះមានឈ្មោះអ្វី? *(បារទីមេ)*

២. តើគាត់កំពុងធ្វើអ្វីនៅពេលដែលព្រះយេស៊ូវបានធ្វើដំណើរឆ្លងកាត់ទីនោះ? *(សុំទាន)*

៣. តើបារទីមេបានធ្វើអ្វីមួយដើម្បីឲ្យគាត់សាកសមនឹងទទួលបានការប្រោសឲ្យជាដែរឬទេ? *(ទេ)*

៤. តើយើងសមនឹងទទួលបានការសង្គ្រោះ និងឡើងទៅឯនគរស្ថានសួគ៌ដែរឬទេ? *(ទេ)*

៥. តើយើងត្រូវធ្វើដូចម្ដេចដើម្បីទទួលបានការសង្គ្រោះ? *(តាមរយៈសេចក្ដីជំនឿលើព្រះដែលបានបញ្ជូនព្រះយេស៊ូវមកសុគតលើឈើឆ្កាងដើម្បីអំពើបាបរបស់យើង)*

### ៧. ល្បែងកំសាន្ត «មនុស្សពិការភ្នែកគូសរូប»

សម្ភារៈដែលត្រូវការ៖ ក្រដាស និងប៊ិក



១. ចែកកុមារជាពីរក្រុម

២. សូមឲ្យក្រុមនីមួយៗរើសកុមារម្នាក់តំណាងឲ្យសមាជិកក្រុមរបស់ពួកគេ។

៣. រុំភ្នែករបស់កុមារទាំងពីរនាក់។

៤.ឲ្យក្រដាសនិងប៊ិកទៅកុមារទាំងពីរនាក់នោះ ហើយប្រាប់ពួកគេឲ្យគូររូបអ្វីមួយ (ឧទាហរណ៍៖ ផ្លែប៉ោម ស្វាយ ចេក ដើមឈើ ផ្កា ត្រី បក្សី ។ល។)

៥. កុមារណាដែលគូសបានល្អជាងគឺជាអ្នកឈ្នះ។

៦. សូមបន្តលេងល្បែងនេះរហូតដល់អស់ពាក្យនៅក្នុងឧទាហរណ៍។

៧. សូមពន្យល់កុមារថា វាពិតជាពិបាកខ្លាំងណាស់ក្នុងការរស់នៅ ប្រសិនបើអ្នកពិការភ្នែក។ ព្រះយេស៊ូវមិនចង់ឲ្យយើងរស់នៅក្នុងស្ថានភាពងងឹតភ្នែក ពិការរូបរាងកាយឬក៏ ប្រលឹងវិញ្ញាណនោះឡើយ។

### ៨. ខគម្ពីរចងចាំ

**កិច្ចការ ១០៖៣៨** *"គឺពីព្រះយេស៊ូវ ពីស្រុកណាសារ៉ែត ដែលព្រះបានចាក់ព្រះវិញ្ញាណ បរិសុទ្ធ និងព្រះចេស្ដាឲ្យមកសណ្ឋិតលើទ្រង់ ហើយទ្រង់បានយាងចុះឡើងធ្វើការល្អ ព្រមទាំងប្រោសឲ្យ អស់អ្នក ដែលត្រូវអារក្សសង្កត់សង្កិនបានជាផង ដ្បិតព្រះបានគង់ជាមួយនឹងទ្រង់"*។

### ៩. ហត្ថកម្ម

សូមផាត់ពណ៌ "ព្រះយេស៊ូវប្រោសមនុស្សខ្វាក់ឲ្យជា"។

### ១០. ចំរៀង *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

### ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្ដើមបង្រៀន)**
មនុស្សអាចពិការរូបរាងកាយឬក៏ប្រលឹងវិញ្ញាណ។ នៅពេលដែលប្រលឹងវិញ្ញាណរបស់យើងខ្វាក់ យើងនឹងមិនអាចមើលឃើញពីការអស្ចារ្យដែលព្រះបានធ្វើនោះទេ។ ព្រះយេស៊ូវតែងតែធ្វើការនៅក្នុងជីវិត រស់នៅរបស់យើង និងមានព្រះបន្ទូលមកកាន់យើង។ តើវាគួរឲ្យសោកស្ដាយប៉ុនណា ប្រសិនបើយើងមិនអាចមើលឃើញពីកិច្ចការដ៏អស្ចារ្យរបស់ព្រះនោះ នេះគឺដោយសារតែយើងបានខ្វាក់ខាងឯប្រលឹងវិញ្ញាណ។ ថ្ងៃនេះសូមឲ្យអ្នកបានអធិស្ឋានទូលសូមទៅ ព្រះឲ្យទ្រង់បានបើកភ្នែកខាងឯព្រលឹងវិញ្ញាណរបស់អ្នក ដើម្បីឲ្យអ្នកអាចមើលឃើញព្រះនិងសេចក្ដីស្រលាញ់ របស់ព្រះអង្គដែលមានចំពោះរាស្ត្ររបស់ទ្រង់។

# ព្រះយេស៊ូវប្រោសមនុស្សខ្វាក់ឲ្យជា



សូមសរសេរខគម្ពីរចងចាំៈ____________________________